វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខៈ ០៩៩ប្រក/ថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០០២

# ប្រកាសស្តីពីការរៀបចំលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីព្រះសីហនុ
# និងសមាសភាពគណៈកម្មការសុរិយោដីខ័ណ្ឌព្រះសីហនុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជា-ណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៧អនក្រ/បកចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈកម្មការ សុរិយោដី
- បានឃើញអនុក្រឹត្យលេខ ៣៤៧ អនក្រ.តត ចុះថ្ងៃទី១៧ ខែកកដា ឆ្នាំ ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការ សុរិយោដីថ្នាក់ជាតិ
- យោងប្រកាសអន្តរក្រសួងលេខ០៧៧ប្រក.ចុះថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ខេត្ត- ក្រុង
- តាមសំណើររបស់គណៈកម្មការសុរិយោដីក្រុងព្រះសីហនុ

## សំរេច

ប្រការ១:

ត្រូវបានបង្កើតលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដី ក្រុងព្រះសីហនុ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- លោក ឌី កាលីនី | អនុប្រធានមន្ទីរ ដនសស.ក្រុងព្រះសីហនុ | ជាប្រធាន |
| ២- លោក ពូន ចលនា | ប្រធានការិយាល័យសុរិយោដីនិងភូមិសាស្ត្រនៃមន្ទី ដនសស.ក្រុងព្រះសីហនុ | ជាអនុប្រធាន |
| ៣- លោក ស្រ៊ុន ម៉ាប់ | អនុប្រធានការិយាល័យសុរិ.និងភូមិសាស្ត្រនៃមន្ទីដនសស.ក្រុងព្រះសីហនុ | ជាមន្ត្រីជំនួយការ |
| ៤- លោក ដួង ច័ន្ទបូរ | អនុប្រធានការិយាល័យសុរិ.និងភូមិសាស្ត្រនៃមន្ទីដនសស.ក្រុងព្រះសីហនុ | ជាមន្ត្រីជំនួយការ |
| ៥- លោក ណុប មន្ទីរិទ្ធ | មន្ត្រីនៃមន្ទីរដនសស.ក្រុងព្រះសីហនុ | ជាមន្ត្រីជំនួយការ |

ប្រការ ២:

ត្រូវបានរៀបចំសមាសភាពគណៈកម្មការសុរិយោដីខ័ណ្ឌក្នុងក្រុងព្រះសីហនុដូចខាងក្រោម :

ក. គណៈកម្មការសុរិយោដីខ័ណ្ឌមិត្តភាព :

| | | |
|---|---|---|
| ១- លោក ជិន សុឃិន | ប្រធានការិយាល័យ.ដនសភ ខ័ណ្ឌមិត្តភាព | ជាប្រធាន |

Downloaded from http://www.khmerlaws.com

| | | |
|---|---|---|
| ២- លោក មិន ម៉ូន | អនុប្រធានការិ. ដនសភ ខ័ណ្ឌមិត្តភាព | ជាសមាជិក |
| ៣- លោក ខាត់ ប៊ុណ្ណ | អនុប្រធានការិ. ដនសភ ខ័ណ្ឌមិត្តភាព | ជាសមាជិក |
| ៤-លោក អ៊ុន ប៊ុន សុង | មន្ត្រីការិយាល័យ .ដនសភ ខ័ណ្ឌមិត្តភាព | ជាសមាជិក |

ខ. គណៈកម្មការសុរិយោដីខ័ណ្ឌស្ទឹងហាវ :

| | | |
|---|---|---|
| ១- លោក រស់ សុគន្ធ | ប្រធានការិយាល័យ ដនសភ ខ័ណ្ឌស្ទឹងហាវ | ជាប្រធាន |
| ២- លោក សិរិទ្ធិ កុសល | អនុប្រធានការិយាល័យ .ដនសភ ខ័ណ្ឌស្ទឹងហាវ | ជាសមាជិក |

គ. គណៈកម្មការសុរិយោដីខ័ណ្ឌព្រៃនប់ :

| | | |
|---|---|---|
| ១- លោក គី សេង | ប្រធានការិយាល័យ.ដនសភ ខ័ណ្ឌព្រៃនប់ | ជាប្រធាន |
| ២- លោក ទ្រី សុផល | អនុប្រធានការិយាល័យ ដនសភ ខ័ណ្ឌព្រៃនប់ | ជាសមាជិក |
| ៣- លោក ម៉ែន សំអាត | មន្ត្រីការិយាល័យ ដនសភ ខ័ណ្ឌព្រៃនប់ | ជាសមាជិក |

ប្រការ៣:

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីក្រុង គណៈកម្មការសុរិយោដីខណ្ឌ័ទាំងអស់ក្នុងក្រុងព្រះសីហនុ មានបេសកកម្មអនុវត្តនូវភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងអនុក្រឹត្យលេខ ៤៧ អនក្រ.បកចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

ប្រការ ៤:

នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មាការសុរិយោដីក្រុងព្រះសីហនុ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តកណ្តាល អស់លោកដូចមានរាយនាមក្នុង ប្រការ១ និង ប្រការ ២ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

Downloaded from http://www.khmerlaws.com